## ជម្រើស និង សំណាង ?

សួរ ផ្ទុយ ទៅ វិញ ថា បើ គ្មាន លោភចិត្ត នៅ ក្នុង ការតស៊ូនយោបាយ តើ វា មាន សេចក្ដីស្រើបចិត្ត ដែរ ឬទេ សំរាប់ អ្នក តស៊ូ ? លោភចិត្ត វា អាស្រ័យ ទៅ លើ គោលដៅ កំណត់, បើ វា សំរាប់ បំរើ អត្ថប្រយោជន៏ បុគ្គល, នៅ ក្នុង ករណី បែប ហ្នឹង វា ជា ការលោភលន់ ដើម្បី ប្រយោជន៏ ផ្ទាល់ ខ្លួន។ នៅ ក្នុង ចំណោម អ្នក តស៊ូ នយោបាយ វា ច្បាស់ ជា មាន អ្នក លោភលន់ ពួន ខ្លួន រក ប្រយោជន៏ ដូច គ្នា នឹង ភិក្ខុ លាក់ អាត្មា នៅ ក្នុង សហជម្និក នូវ អ្នក ដឹកនាំ ជាតិ ប្រើ អំណាច រដ្ឋ ដើម្បី អញ នោះ ដែរ ព្រោះ ការលោភលន់ វា មាន នៅ ក្នុង ធម្មជាតិ របស់ មនុស្សលោក។ តិកៈ[1] នេះ ពិត ជា មនុស្ស តែ ពួក គាត់ ជ្រើសរើស ផ្លូវ ពាល ដោយ ស្ម័គ្រចិត្ត ដែល វា ក្លាយ ទៅ ជា ធម្មជាតិ ទី២ របស់ ពួក គាត់ ដែល គេ ហៅ ថា តិរច្ឆាន។ ពិត ណាស់ ហើយ ថា មនុស្ស ក៏ ជា សត្វ ដែរ តែ មាន ចិត្ត ជំពាក់ ក្នុង អារម្មណ៏ ផ្សេងៗ ក្នុង នោះ វា មាន ល្អ វា មាន អាក្រក់។ សេរីភាព ក្នុង ជម្រើស យក ផ្លូវ ណា មួយ នេះ ឯង ដែល បែងចែក មនុស្ស និង តិរច្ឆាន។ ត្រូវ ដឹង ដែរ ថា បើ មនុស្ស ណា ម្នាក់ និយាយ ថា គាត់ គ្មាន ជម្រើស រវាង ផ្លូវ ល្អ និង អាក្រក់ យើង អាច សួរ ថា តើ មនុស្ស នោះ ជា អ្វី ? មាន គំនិត ល្អ ទើប មាន សំណាង ល្អ ព្រោះ សំណាង វា មិន ពឹង បុណ្យ គេ នោះឡើយ។

[1] តិកៈ : ចំនួន ៣, ពួក ៣។